# ពត៌មានអំពីជំនួយសំរាប់ការរស់នៅដោយខ្លួនឯង

**ក្រុមជំនួយសំរាប់មនុស្សចាស់នៅសង្កាត់ហ្វ្រ៊ែងគ្លិន** គឺជាកន្លែងមួយដែលផ្តល់ពត៌មាននិងមានទំនាក់ទំនងជាមួយសមាគមន៍នានា
ដែលអាចជួយដល់អ្នកជរាដែលជាប្រជាជននៅសង្កាត់ហ្វ្រិងគ្លិនដែលមានអាយុ
លើសពីហុកសិបឆ្នាំ ដើម្បីនឹងអាចរស់នៅដោយខ្លួនឯងបាន។
ក្រុមជំនួយចំពោះចា ស់ៗនេះ បានទទួលប្រាក់ជំនួយពីរដ្ឋសំរាប់ចាស់ៗនិងប្រាក់ចំនួយផ្សេងៗទៀត

## មានជំនួយជាច្រើនខាងក្រោមនេះដែលអាចជួយដល់អ្នកគឺ:

- ជួយផ្តល់ពត៌មានផ្សេងៗ
- ជួយយត្រួតពិនិត្យសំណុំរឿង
- ជមន្ទួយតាមផ្ទះ
- ការត្រូវការផ្ទាល់ខ្លួនរបស់អ្នក
- អ្នកថែទាំអ្នក
- ការជួសជុលផ្ទះបន្តិចបន្តួច
- ប្រដាប់ឲ្យដំណឹងនៅពេលមានភាពអាសន្ន
- ការធ្វើដំណើរទៅមន្ទីពេទ្យ
- ថែរក្សាចាស់ៗនៅពេលថ្ងៃ
- ការចែកម្ហូបតាមផ្ទះ

FRANKLIN COUNTY
Senior Options

បើលោកអ្នកមានសំនួរផ្សេងៗអំពីការបំរើចាស់ៗឬគំរោងការផ្សេងៗដែលមាននៅសង្កាត់ហ្វ្រឹងក្លិន

**សូមទូរសព្ទលេខ: ២៦៧-៨៨៩៩ 267-8899**

Franklin County Office on Aging
*an agency of the*
Franklin County Commissioners
Paula Brooks • Marilyn Brown • John O'Grady

# កិច្ចការបម្រើជាជំនួយដល់មនុស្សចាស់

**ការផ្តល់ពត៌មានផ្សេងៗ:** *ពត៌មានផ្សេងៗនៃសមាគមន៍នានាដែលជួយចាស់ៗត្រូវផ្សាយជាសាធារណៈ។*
**ការត្រួតពិនិត្យសំណុំរឿង:** *មានអ្នកត្រួតពិនិត្យសំណុំរឿងជាបន្តបន្ទាប់ជាមួយមនុស្សចាស់*
*ដើម្បីឲ្យបានដឹងថាគាត់បានទទួលជំនួយពីសមាគមន៍ផ្សេងៗដោយត្រឹមត្រូវ។*
**ជំនួយតាមផ្ទះ:** *មានអ្នកជួយដល់អ្នកដែលជរាពិការឲ្យបានស្អាត ឲ្យកន្លែងបានសុខស្រួលស្រួល ដោយមានគេជួយសំអាតផ្ទះនិងសំលៀកបំពាក់។*
**ការជួយនៅពេលថ្ងៃនៃការគ្រប់គ្រងការផ្ទាល់ខ្លួនរបស់អ្នក:** *គម្រោងការនេះតម្រូវឲ្យជួយមនុស្ស*
*ចាស់ដែលពិការតិចតួចដោយរបៀបការពារ។ គម្រោងការជំនួយនេះដូចជា ការថែទាំសុខភាព ការថែរក្សាខ្លួន ម្ហូបអាហារ*
*ការធ្វើដំណើរទៅកន្លែងណាមួយ។ គម្រោងការខ្លះ អាចជួយពីទំនាក់ទំនងក្នុងសង្គម និងជួយពង្រឹងសុខភាព ថែមទៀតផង។*
**ការចែកម្ហូបតាមផ្ទះ:** *ម្ហូបអាហារដ៏ល្អសម្រាប់សុខភាព ត្រូវចែកជូនដល់មនុស្សចាស់ទៅតាមផ្ទះ ដើម្បីឲ្យគាត់មានសុខភាពល្អ។*
*ម្ហូបក្តៅៗសម្រាប់ពេលថ្ងៃត្រង់ មានពីថ្ងៃច័ន្ទរហូតដល់ថ្ងៃសុក្រ។*
*ម្ហូបត្រជាក់សម្រាប់ពេលល្ងាចឬសម្រាប់ថ្ងៃសៅរ៍ឬថ្ងៃអាទិត្យអាចនឹងចែកជូនបានដែរ។*
**មានអ្នកដែលថែរក្សាអ្នក:** *មានអ្នកដែលមានការហ្វឹកហ្វឺនរួចមកហើយសំរាប់ឲ្យជួយមនុស្សចាស់នៅផ្ទះ*
*ដែលត្រូវការជំនួយ២៤ម៉ោងជារៀងរាល់ថ្ងៃ។*
**ការធ្វើដំណើរទៅពេទ្យ:** *ការជូនដំណើរទៅមើលសុខភាពសំរាប់មនុស្សចាស់ មានកៅអីសំរាប់អ្នកពិការ*
*ព្រមទាំងមានមនុស្សម្នាក់ជូនដំណើរផង។*
**ប្រដាប់ឲ្យដំណឹងនៅពេលមានភាពអាសន្ន:** *ដើម្បីការពារមនុស្សចាស់ឲ្យបានសុខសាននៅផ្ទះ*
*ដោយមានទំនាក់ទំនងតាមប្រដាប់អេឡិចត្រូនិចទៅនិងកន្លែងជំនួយនៅពេលមានភាពអាសន្ន ។*
**ការជួសជុលផ្ទះតិចតួច:** *មានជំនួយក្នុងការជួសជុលផ្ទះផ្សេងៗដលអាចជួយបានទៅតាមផ្ទះមនុស្សចាស់*
*ដើម្បីឲ្យគាត់រស់នៅបានសុខសប្បាយដោយខ្លួនឯង។*
**ការជួសជុលផ្ទះតិចតួច:**
*មានជំនួយក្នុងការជួសជុលផ្ទះផ្សេងៗ ដែលអាចជួយបានទៅតាមផ្ទះមនុស្សចាស់ ដើម្បីឲ្យគាត់រស់នៅបានសុខសប្បាយដោយខ្លួនឯង។*